**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៣៤ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការចាត់តាំងសមាជិករាជរដ្ឋាភិបាល ដើម្បីចូលរួមជាអធិបតីក្នុងពិធី ប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

ប្រការ ១.-

ត្រូវបានចាត់តាំងសមាសភាពសមាជិករាជរដ្ឋាភិបាល ដើម្បីចូលរួមជា **អធិបតី** ក្នុងពិធីប្រកាសចូលកាន់តំណែងក្រុមប្រឹក្សា និង គណៈអភិបាលរាជធានី និង ខេត្ត នៅតាមបណ្តារាជធានី និង ខេត្ត ដូចខាងក្រោម ៖

១- ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមនៅរាជធានីភ្នំពេញ និង ខេត្តបាត់ដំបង

២- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីចូលរួមនៅខេត្តតាកែវ

៣- ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ចូលរួមនៅខេត្តសៀមរាប

៤- ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមនៅខេត្តកណ្តាល

៥- លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ ចូលរួមនៅខេត្តស្វាយរៀង

៦- ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចូលរួមនៅខេត្តបន្ទាយមានជ័យ

៧- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ចូលរួមនៅខេត្តកំពង់ធំ

៨- ឯកឧត្តម **ម៉ែន ឈិន** ឧបនាយករដ្ឋមន្ត្រី ចូលរួមនៅខេត្តព្រៃវែង ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ

៩- ឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ចូលរួមនៅខេត្តកំពង់ចាម

១០- ឯកឧត្តម **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ចូលរួមនៅខេត្តពោធិសាត់

១១- ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានចូលរួមនៅខេត្តព្រះសីហនុ

១២- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចូលរួមនៅខេត្តកំពង់ឆ្នាំង

១៣- ឯកឧត្តម **អ៊ឹម សេធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចូលរួមនៅខេត្តរតនគិរី និងខេត្តស្ទឹងត្រែង

១៤- ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ចូលរួមនៅខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន

១៥- ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចូលរួមនៅខេត្តកំពង់ស្ពឺ

១៦- ឯកឧត្តម **នុត សាអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចូលរួមនៅខេត្តកោះកុង

១៧- ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចូលរួមនៅខេត្តកំពត និងខេត្តកែប

១៨- ឯកឧត្តម **ទី ចន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចូលរួមនៅខេត្តព្រះវិហារ ។

ប្រការ ២.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចរៀបចំកម្មវិធីលំអិត និង ចាត់តាំងមន្ត្រីចូលរួមក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និង គណៈអភិបាលរាជធានី និង ខេត្ត នៅតាមបណ្តារាជធានី និង ខេត្ត ដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ។

ប្រការ ៣.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចប្រការ ៣*
- *ឯកសារ កាលប្បវត្តិ*